# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ៥៤០/០៧ គ.ជ.ប

## សេចក្តីណែនាំ
### ស្តីពីការបិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត (ទម្រង់ ១០២៥)
### នៅគ្រប់ភូមិក្នុងគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស

**យោង** :
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ។
- សេចក្តីណែនាំរួមលេខ ០១១ ស.ណ.ន របស់ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៥ ស្តីពីការរៀបចំត្រៀមបម្រើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។
- សេចក្តីណែនាំ លេខ ៣៣១/០៧ គ.ជ.ប និង ៣៣២/០៧ គ.ជ.ប ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៧ ។

ដើម្បីឱ្យការផ្សព្វផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោត (ទម្រង់ ១០២៥) ជូនដល់ប្រជាពលរដ្ឋបានកាន់តែទូលំទូលាយនៅគ្រប់ភូមិក្នុងគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស គ.ជ.ប សូមអស់លោក លោកស្រី ប្រធាន លខ/កប ទាំងអស់ណែនាំក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងមេភូមិឱ្យអនុវត្តការងារមួយចំនួន ដូចខាងក្រោម៖

១- ស្មៀនឃុំ សង្កាត់ត្រូវថតចម្លងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោត (ទម្រង់ ១០២៥) តាមចំនួនដូចខាងក្រោម៖
- មួយ (១) ច្បាប់ ដើម្បីផ្ញើមក គ.ជ.ប តាម លខ/កប
- ពីរ (២) ច្បាប់ សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីទុកប្រើប្រាស់តាមការណែនាំរបស់ គ.ជ.ប
- មួយ (១) ច្បាប់ៗ សម្រាប់ភូមិនីមួយៗបិទផ្សាយ ។

២- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្សព្វផ្សាយដល់គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់អំពីការបិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោត នៅគ្រប់ភូមិក្នុងឃុំ សង្កាត់ និងត្រូវណែនាំមេភូមិ ពាក់ព័ន្ធក្នុងឃុំ សង្កាត់ឱ្យបិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោត (ទម្រង់១០២៥) នៅទីស្នាក់ការភូមិ ឬទីប្រជុំជនណាមួយក្នុងភូមិ ។ ការបិទផ្សាយទម្រង់ ១០២៥ នៅតាមភូមិត្រូវធ្វើជាបន្ទាន់ បន្ទាប់ពីការថតចម្លងការណែនាំ និងបែងចែកដល់មេភូមិហើយ ។

៣- មេភូមិត្រូវយកចិត្តទុកដាក់បិទផ្សាយខិត្តប័ណ្ណ "សូមចូលរួមការត្រៀមសំអាតបញ្ជីបោះឆ្នោត" ឬ "ខិត្តប័ណ្ណអំពាវនាវ" របស់ គ.ជ.ប រួមជាមួយនឹងទម្រង់ ១០២៥ ផង និងត្រូវផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីទីកន្លែងដែលត្រូវបិទផ្សាយនៅក្នុងភូមិ ។

ទទួលបានសេចក្តីណែនាំនេះ សូមអស់លោក លោកស្រី ប្រធាន លខ/កប យកចិត្តទុកដាក់ផ្សព្វផ្សាយជាបន្ទាន់ និងសហការអនុវត្តឱ្យមានប្រសិទ្ធភាព ។

ភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៧

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។\

ប្រធាន

អ៊ឹម សូស្ឌី